សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ្វូមី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

១៧ មករា ២០១២

**សូមគោរព លោក គុជ រូសាល នាយកប្រតិបត្តិអង្គការស្តាបនាកម្ពុជា!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលមានវត្តមានក្នុងពិធីចុះហត្ថលេខាជាមួយ អង្គការស្តាបនាកម្ពុជា សម្រាប់គម្រោងជំនួយដើម្បីសាងសង់អាងស្តុកទឹកភ្លៀង ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង។

ជំនួយដែលមានទឹកប្រាក់សរុបចំនួន១០៨,៩០០ដុល្លាអាមេរិក ត្រូវបានផ្តល់ជូនអង្គការស្តាបនាកម្ពុជានៅថ្ងៃនេះដើម្បីសាងសង់អាងស្តុកទឹកភ្លៀង និងតម្រងចម្រោះទឹកនៅសាលាបឋមសិក្សាចំនួន១៦ក្នុង ស្រុកសង្កែ ខេត្តបាត់ដំបង។ សិស្សានុសិស្សនៃសាលាទាំងនេះមានបញ្ហាសុខភាពជាច្រើនដែលបង្កមកពីកង្វះទឹកស្អាត។ គម្រោងនេះនឹងជួយកែលម្អគុណភាពទឹកដែលមានសុវត្ថិភាពសម្រាប់ផឹក ហើយសិស្សានុសិស្ស និង គ្រូបង្រៀនជាង៨,៧០០នាក់ដែលនៅក្នុងសាលាទាំងនោះ នឹងទទួលបានអត្ថប្រយោជន៍។

ការទទួលបានទឹកមានសុវត្ថិភាព គឺជាគោលដៅមួយនៃបណ្តាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា ហើយវាក៏ជាមូលដ្ឋាននៃលក្ខខណ្ឌសុខភាពល្អ។ ដោយសារវាជាវិស័យអាទិភាពមួយក្នុងការផ្តល់ជំនួយ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តគាំទ្រដល់ការធ្វើឲ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង និងតំបន់ជនបទក្នុងប្រទេសកម្ពុជា។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងរួមចំណែកដល់ការទទួលបានទឹកស្អាត និងមានសុវត្ថិភាពដើម្បីប្រើប្រាស់ ហើយ និងជួយឲ្យលក្ខខណ្ឌសុខភាពរបស់កុមារដែលរស់នៅក្នុងស្រុកសង្កែ កាន់តែប្រសើរឡើង។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្នើដល់លោក-អ្នកជាតំណាងសាលាទាំងអស់សូមប្រើប្រាស់ អាងស្តុកទឹកភ្លៀង និង តម្រងចម្រោះទឹកឲ្យបានត្រឹមត្រូវ និងសូមថែរក្សាឲ្យបានជាប្រចាំដើម្បីធានាគុណភាពទឹកក្នុងរយៈពេលយូរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនង មិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!